# បុរស, ស្ត្រី និងភាពសមធម៌តាមព្រះបន្ទូលព្រះជាម្ចាស់

## គ្រីស្តបរិស័ទ ដើម្បីភាពសមធម៌តាមព្រះបន្ទូលព្រះជាម្ចាស់

ព្រះគម្ពីរបង្រៀនពីភាពស្មើគ្នាទាំងស្រុងនៃបុរស និងស្ត្រីចំពោះរបស់សព្វសារពើ និងការប្រោសលោះ (កំណើត 1:26-28, 2:23, 5:1-2, 1កូរិន 11:11-12, កាឡាទី 3:13, 28, 5:1)

ព្រះគម្ពីរបានប្រាប់ថា ព្រះជាម្ចាស់បានសម្តែងខ្លួនទ្រង់ផ្ទាល់យ៉ាងពេញលេញនៃព្រះគម្ពីរ ដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដ៏មានអំណាច (ម៉ាថាយ 5:18, យ៉ូហាន 10:35, 2ធីម៉ូថេ 3:16, 2ពេត្រុស 1:20-21)។ យើងជឿជាក់ថា ព្រះគម្ពីរនឹងត្រូវបានបកប្រែយ៉ាងគ្រប់ជ្រុងជ្រោយ និងយ៉ាងចំប្រធានបទ។ យើងក៏ទទួលស្គាល់ពីសារៈសំខាន់នៃការធ្វើឲ្យមានភាពខុសគ្នារវាងការជម្រុញចិត្ត និងការបកស្រាយផងដែរ ដែលការជម្រុញចិត្តទាក់ទងនឹងការដាស់តឿនចិត្ត និងអំណាចគ្រប់គ្រងបែបព្រលឹងវិញ្ញាណ ដែលស្ថិតនៅក្នុងគោលការណ៍ព្រះគម្ពីរទាំងមូល ដែលជាព្រះបន្ទូលនៃព្រះជាម្ចាស់។ ការបកស្រាយទាក់ទងនឹងសកម្មភាពរបស់មនុស្ស ដែលជារបៀបមួយក្នុងការព្យាយាមស្វែងយល់ពីសេចក្តីពិត ដែលលាក់កំបាំងដោយមានលក្ខណៈចុះសម្រុងជាមួយភាពពេញលេញនៃព្រះគម្ពីរ ហើយស្ថិតនៅក្រោមការណែនាំនៃព្រះវិញ្ញាណបរិសុទ្ធ។ ដើម្បីឲ្យមានភាពពិតប្រាកដតាមគោលការណ៍ព្រះគម្ពីរ គ្រីស្តបរិស័ទត្រូវតែពិនិត្យមើលជំនឿរបស់យើងយ៉ាងជាប់លាប់ ហើយអនុវត្តជំនឿរបស់ខ្លួន ដែលស្ថិតក្រោមការបំភ្លឺនៃព្រះគម្ពីរ។

### សេចក្តីពិតតាមគោលការណ៍ព្រះគម្ពីរ

### ការបង្កើត

១. ព្រះគម្ពីរបានចែងថា ទាំងបុរស និងស្ត្រីត្រូវបានបង្កើតមកឲ្យមានលក្ខណៈដូចព្រះជាម្ចាស់ ដោយមានទំនាក់ទំនងផ្ទាល់ជាមួយព្រះអង្គ ហើយបានរួមគ្នាទទួលខុសត្រូវក្នុងការបង្កើត និងមើលថែទាំកូន ហើយមានអំណាចលើសត្តនិករទាំងឡាយ (កំណើត 1:26-28)។

២. ព្រះគម្ពីរបានបង្រៀនថា ស្ត្រី និងបុរសត្រូវបានបង្កើតមកដើម្បីជាដៃគូបំពេញគ្នា និងស្មើគ្នា។ ពាក្យថា "អ្នកជំនួយ" (អ៊ីស្ស៊ី) ត្រូវបានប្រើប្រាស់ដើម្បីកំណត់នាមស្ត្រី នៅក្នុងសៀវភៅកំណើតពិភពលោក 1:18 ដែលសំដៅចំពោះព្រះជាម្ចាស់នៅក្នុងស្ថានភាពភាគច្រើននៃការប្រើប្រាស់ក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ (ឧ. ១សាំយ៉ូអែល 7:12, ទំនុកតម្កើង 121:1-2)។ ហេតុដូច្នេះហើយ ពាក្យនេះមិនសំដៅចំពោះភាពអន់ខ្សោយ ឬភាពក្រោមបង្គាប់របស់ភេទស្រីនោះឡើយ។

៣. ព្រះគម្ពីរបានបង្រៀនថា ការបង្កើតស្ត្រីមកពីខ្លួនបុរសបង្ហាញពីភាពសាមគ្គី និងភាពស្មើគ្នាជាមូលដ្ឋាននៃមនុស្ស (កំណើត 1:21-23)។ នៅក្នុងសៀវភៅកំណើតពិភពលោក 2:18, 20 ពាក្យថា "សាកសម" (គេនិកដូ) បង្ហាញអំពីភាពស្មើគ្នា និងភាពគ្រប់គ្រាន់។

៤. ព្រះគម្ពីរបានបង្រៀនថា បុរស និងស្ត្រី គឺជាអ្នកសមគំនិតចូលរួមក្នុងការប្រឆាំងទាស់នឹងព្រះជាម្ចាស់ ដែលទាំងអដាំ និងអេវ៉ាសាកសមនឹងទទួលកំហុសស្មើគ្នា (កំណើត 3:6, រ៉ូម 5:12-21, ១កូរិន 15:21-22)។

៥. ព្រះគម្ពីរបានបង្រៀនថា ការដឹកនាំរបស់អដាំលើនាងអេវ៉ា គឺដោយសារតែការប្រឆាំងទាស់នឹងព្រះជាម្ចាស់ ហេតុនេះហើយទើបសេចក្តីនេះមិនមែនជាផ្នែកនៃការបង្កើតមកពីដើមដំបូងនោះ។ នៅក្នុងកំណើតពិភពលោក 3:16 បានចែងពីការថ្លែងទុកជាមុននៃលទ្ធផលពីការប្រឆាំងទាស់នឹងព្រះជាម្ចាស់ ជាជាងថ្លែងពីច្បាប់នៃភាពល្អឥតខ្ចោះនៃព្រះជាម្ចាស់។

**ការប្រោសលោះ**

៦. ព្រះគម្ពីរបានបង្រៀនថា ព្រះយេស៊ូគ្រីស្តបានយាងមកផែនដី ដើម្បីប្រោសលោះស្ត្រី ក៏ដូចជាបុរសផងដែរ។ តាមរយៈជំនឿក្នុងអង្គព្រះគ្រីស្ត យើងទាំងអស់គ្នាអាចទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ដោយរួមក្នុងអង្គព្រះគ្រីស្តតែមួយ ហើយអាចទៅជាអ្នកទទួលមរតកនៃព្រះពរនៃការសង្គ្រោះ ដោយមិនប្រកាន់ភាពខុសគ្នាបែបជាតិសាសន៍ សង្គម ឬភេទនោះឡើយ (យ៉ូហាន 1:12-13, រ៉ូម 8:14-17, 2កូរិនថូស 5:17, កាឡាទី 3:26-28)។

**សហគមន៍**

៧. ព្រះគម្ពីរបានបង្រៀនថា នៅថ្ងៃបុណ្យទីហាសិបព្រះវិញ្ញាណដ៏វិសុទ្ធយាងមកសណ្ឋិតលើបុរស និងស្ត្រីគ្រប់ៗគ្នា។ ដោគ្មានភាពខុសគ្នាឡើយ ព្រះវិញ្ញាណដ៏វិសុទ្ធបានគង់នៅជាមួយទាំងស្ត្រី និងបុរស ហើយបានប្រទានបែងចែកអំណោយទានដ៏អស្ចារ្យ ដោយមិនប្រកាន់ភេទនោះទេ (កិច្ចការ 2:1-21, 1កូរិនថូស 12:7, 11, 14:31)។

៨. ព្រះគម្ពីរបានបង្រៀនថា ទាំងស្ត្រី និងបុរសត្រូវបានត្រាស់ហៅ ដើម្បីអភិវឌ្ឍអំណោយទានផ្នែកព្រលឹងវិញ្ញាណ និងប្រើប្រាស់អំណោយទានទាំងនោះ ក្នុងនាមជាអ្នកទទួលរ៉ាប់រងនៃព្រះគុណរបស់ព្រះជាម្ចាស់ (1ពេត្រុស 4:10-11)។ ទាំងស្ត្រី និងបុរសបានទទួលអំណោយទាន និងសិទ្ធិអំណាចពីព្រះជាម្ចាស់ ដើម្បីធ្វើកិច្ចការសម្រាប់ព្រះកាយនៃព្រះគ្រីស្តទាំងមូល ដោយស្ថិតក្រោមអំណាចគ្រប់គ្រងរបស់ព្រះអង្គ (កិច្ចការ 1:14, 18:26, 21:9, រ៉ូម 16:1-7, 12-13, 15, ភីលីព 4:2-3, កូឡូស 4:15, ម៉ាកុស 15:40-41, 16:1-7, លូកា 8:1-

3,  យ៉ូហាន  20:17-18, ដោយប្រៀបធៀបជាមួយឧទាហរណ៍នៅក្នុងព្រះគម្ពីរសញ្ញាចាស់ផងដែរ ពង្សាវតា 4:4-14, 5:7, 2របាក្សត្រ 34:22-28, សុភាសិត 31:30-31, មីកា 6:4)។

៩. ព្រះគម្ពីរបានបង្រៀនថា នៅក្នុងសេដ្ឋកិច្ចនៃព្រះគម្ពីរសញ្ញាថ្មី ទាំងស្ត្រី និងបុរសបានអនុវត្តតួនាទីក្នុងការថ្លែងពាក្យទំនាយ ថ្លែងព្រះបន្ទូល និងតួនាទីនៃមហាក្សត្រ (កិច្ចការ 2:17-18, 21:9, 1កូរិនថូស 11:5, 1ពេត្រុស 2:9-10, វិវរណៈ 1:6, 5:10)។ ដូច្នេះអត្ថបទគម្ពីរផ្សេងមួយចំនួន ដែលបង្ហាញពីការកំហិតដល់សេរីភាពនៃការប្រោសលោះយ៉ាងពេញលេញចំពោះស្ត្រី នឹងមិនត្រូវបានបកស្រាយឲ្យមានលក្ខណៈស្មុគស្មាញនោះទេ ហើយក៏មិនឲ្យមានលក្ខណៈផ្ទុយពីខនៃព្រះគម្ពីរផ្សេងៗទៀតដែរ ប៉ុន្តែត្រូវតែមានការយកចិត្តទុកដាក់ចំពោះការបកស្រាយរបស់ពួកគេ ដែលទាក់ទងនឹងការបង្រៀនព្រះគម្ពីរទាំងមូល និងបរិបទទាំងស្រុងរបស់ពួកគេ (1កូរិនថូស 11:2-16, 14:33-36, 1ធីម៉ូថេ 2:9-15)។

១០. ព្រះគម្ពីរបានកំណត់តួនាទីនៃការដឹកនាំថា ជាការផ្តល់សិទ្ធិអំណាចដល់អ្នកដទៃ ដើម្បីការបម្រើ ជាជាងថាវាជាការប្រើប្រាស់អំណាចត្រួតត្រាលើមនុស្ស (ម៉ាថាយ 20:25-28, 23:8, ម៉ាកុស 10:42-45, យ៉ូហាន 13:13-17, កាឡាទី 5:13, 1ពេត្រុស 5:2-3)។

## ក្រុមគ្រួសារ

១១. ព្រះគម្ពីរបានបង្រៀនថា ប្តី និងប្រពន្ធគឺជាអ្នកទទួលកេរ្តិ៍មរតកនូវព្រះគុណនៃជីវិតទាំងអស់គ្នា ហើយថាពួកគេត្រូវបានចង់ភ្ជាប់ជាមួយគ្នាចំពោះទំនាក់ទំនងនៃការចុះចូល និងការទទួលខុសត្រូវគ្នាទៅវិញទៅមក (1កូរិនថូស 7:3-5, អេភេសូ 5:21, 1ពេត្រុស 3:1-7, កំណើត 21:12)។ តួនាទីរបស់ប្តី ក្នុងនាមជា "ក្បាល" (គេពហាឡេ) ត្រូវតែយល់ពីសេចក្តីស្រឡាញ់ ដែលឲ្យអ្វីដែលខ្លួនមាន និងបម្រើនៅក្នុងទំនាក់ទំនងនេះចំពោះការចុះចូលគ្នាទៅវិញទៅមក (អេភេសូ 5:21-33, កូរិនថូស 3:19, 1ពេត្រុស 3:7)។

១២. ព្រះគម្ពីរបានបង្រៀនថា  ទាំងម្តាយ និងឪពុកត្រូវអនុវត្តភាពជាអ្នកដឹកនាំចំពោះការចិញ្ចឹមបីបាច់ បណ្តុះបណ្តាល លត់ដំ និងបង្រៀនកូនៗរបស់ពួកគេ (សេរីភាព 20:12, លេវីវិន័យ 19:3, ទុតិយកថា 6:6-9, 21:18-21, 27:16, សុភាសិត 1:8, 6:20, អេភេសូ 6:1-4, កូរិនថូស 3:20, 2ធីម៉ូថេ 1:5, លូកា 2:51)។

# ការអនុវត្តន៍

## សហគមន៍

១.  នៅក្នុងក្រុមជំនុំ អំណោយទានផ្នែកព្រលឹងវិញ្ញាណនៃបុរស និងស្ត្រីត្រូវបានទទួលស្គាល់ អភិវឌ្ឍ និងប្រើប្រាស់ ដើម្បីបម្រើ និងបង្រៀនដល់ព័ន្ធកិច្ចគ្រប់កម្រិតនៃការពាក់ព័ន្ធជាមួយ អ្នកដឹកនាំក្រុមតូចៗ អ្នកប្រឹក្សា

យោបល់ អ្នកសម្របសម្រួល អ្នកធ្វើកិច្ចការរដ្ឋបាល អ្នកទទួលភ្ញៀវ អ្នកជួយក្នុងពិធីកាច់នំប៉័ង និងសមាជិកគណៈកម្មការ និងអ្នកបំពេញកិច្ចការផ្នែកថែទាំកូនចៀម ការបង្រៀន ការអធិប្បាយ និងការថ្វាយបង្គំ។

ក្នុងការបំពេញកិច្ចការទាំងនេះ ក្រុមជំនុំនឹងផ្តល់ព្រះកិត្តិយសដល់ព្រះជាម្ចាស់ ដែលជាប្រភពនៃព្រះអំណោយទានផ្នែកព្រលឹងវិញ្ញាណទាំងនោះ។ ក្រុមជំនុំក៏នឹងបំពេញនូវសិទ្ធិអំណាចនៃព្រះជាម្ចាស់ចំពោះការទទួលរ៉ាប់រងដោយមិនមានអារម្មណ៍នៃការខ្លាចបាត់បង់ចំពោះព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលអាចកើតមានឡើងនៅពេលសមាជិកពាក់កណ្តាលនៃក្រុមជំនុំបោះបង់តួនាទីនៃការទទួលខុសត្រូវរបស់ខ្លួន។

២. នៅក្នុងក្រុមជំនុំ ការបង្ហាញការសរសើរ និងការគោរពជាសាធារណៈនឹងត្រូវផ្តល់ឲ្យទៅដល់ទាំងស្ត្រី និងបុរស ដែលអនុវត្តកិច្ចការងារ នៃការបម្រើ និងការដឹកនាំ។

ការធ្វើដូច្នេះ ក្រុមជំនុំនឹងធ្វើជាគំរូនៃការសាមគ្គី និងភាពសុខដុម ដែលវាគួរតែជាលក្ខណៈរបស់សហគមន៍នៃអ្នកជឿព្រះជាម្ចាស់។ នៅក្នុងលោកិយ ដែលបាក់បែកដោយការរើសអើង និងការបែងចែកបក្សពួក ក្រុមជំនុំនឹងធ្វើឲ្យសាធារណៈដឹងថា ខ្លួនមិនបានញែកខ្លួនចេញពីលោកិយ និងសាសនា ដែលបានរៀបចំឡើង ដើម្បីឲ្យស្ត្រីមានអារម្មណ៍ថាខ្លួនអន់ខ្សោយក្នុងនាមជាជាភេទស្រីនោះឡើយ។ វានឹងជួយរារាំងពួកគេមិនឲ្យចាកចេញពីក្រុមជំនុំ ឬទប់ស្កាត់មិនឲ្យមានការបដិសេដចំពោះជំនឿបែបគ្រីស្តបរិស័ទ។

## ក្រុមគ្រួសារ

៣. នៅក្នុងគ្រួសារគ្រីស្តបរិស័ទ ប្តី និងប្រពន្ធត្រូវតែធ្វើតាម និងស្តាប់គ្នាទៅវិញទៅមក ដើម្បីស្វែងរកការបំពេញចំណង់ចំណូលចិត្ត បំណង និងការជម្រុញទឹកចិត្តគ្នាទៅវិញទៅមក។ ទាំងប្តី ឬប្រពន្ធនឹងមិនត្រូវស្វែងរកអំណាចត្រួតត្រាលើនរណាម្នាក់នោះឡើយ ប៉ុន្តែទាំងពីរនាក់ត្រូវតែបម្រើគ្នាទៅវិញទៅមក ដោយការបន្ទាបខ្លួនដោយគិតថា អ្នកដទៃល្អប្រសើរដូចជាខ្លួនឯងដែរ។ ក្នុងករណីដែលជាប់ស្ទះក្នុងការសម្រេចចិត្តលើអ្វីមួយ ពួកគេគួរតែស្វែងរកដំណោះស្រាយនៃជម្លោះតាមរយៈមធ្យោបាយក្នុងគោលការណ៍ព្រះគម្ពីរ ជាជាងការសម្រេចចិត្តពីសំណាក់ប្តី ឬប្រពន្ធខ្លួនឯង។

ការធ្វើដូច្នេះ ប្តី និងប្រពន្ធនឹងជួយឲ្យគ្រួសារគ្រីស្តបរិស័ទតយុទ្ធចំពោះការប្រើប្រាស់សិទ្ធិអំណាច ដែលមិនត្រឹមត្រូវពីសំណាក់ប្តី ឬប្រពន្ធ ហើយនឹងការពារក្រុមគ្រួសារពីការរំលោភបំពានលើប្រពន្ធ និងកូន ដែលជួនកាលវាមានការបកស្រាយតាមបែបលំដាប់ថ្នាក់យ៉ាងគួរឲ្យសោកស្តាយណាស់ចំពោះ "ភាពដឹកនាំ" របស់ប្តី។

៤. នៅក្នុងគ្រួសារគ្រីស្តបរិស័ទ ប្តីប្រពន្ធត្រូវរៀនចែករំលែកទំនួលខុសត្រូវនៃការដឹកនាំ ដោយយោងតាមអំណោយទាន ឯកទេស និងភាពអាចធ្វើទៅបាន ដោយមានការគោរពចំពោះដៃគូរបស់ខ្លួន ដែលមានឥទ្ធិពល

ខ្លាំងបំផុតតាមរយៈការសម្រេចចិត្ត ស្ថិតក្រោមការពិចារណា។

ការធ្វើដូច្នេះ ប្តីប្រពន្ធនឹងរៀនក្នុងការគោរពសមត្ថភាព និងបំពេញបន្ថែមឲ្យគ្នា។ សេចក្តីនេះនឹងជួយការពារឲ្យប្តី ឬប្រពន្ធមិនទៅជាអ្នកបរាជ័យចំពោះអ្វីមួយដ៏យូរអង្វែង ដែលជាញឹកញាប់ត្រូវបានបង្ខំឲ្យប្រព្រឹត្តការផ្តាប់ផ្តុន ឬការបោកបញ្ឆោត ដើម្បីការពារការឲ្យតម្លៃលើខ្លួនឯង។ តាមរយៈការបង្កើតអាពាហ៍ពិពាហ៍ ដោយស្ថិតលើមូលដ្ឋានដៃគូតែមួយនេះ ប្តីប្រពន្ធនឹងការពារមិនឲ្យមានអាពាហ៍ពិពាហ៍ ដែលបាក់បែក ដែលមកពីអសមធម៌រវាងប្តីប្រពន្ធ។

**៥.** នៅក្នុងគ្រួសារគ្រីស្តបរិស័ទ ប្តីប្រពន្ធ ដែលចែករំលែកគ្នានូវរបៀបរស់នៅ ដែលមានសេរីភាពក្នុងអង្គព្រះគ្រីស្តនឹងធ្វើបានយ៉ាងនោះ ដោយគ្មានពិសោធចំពោះអារម្មណ៍នៃទោសកំហុស ឬការមិនចង់ប្រព្រឹត្តភាពពុតជ្រុត។ ពួកគេមានសេរីភាពពីការប្រព្រឹត្តតាមទម្លាប់ ដែលមិនស្របតាមព្រះបន្ទូលព្រះជាម្ចាស់ ហើយអាចអរសប្បាយជាមួយការមើលខុសត្រូវគ្នាទៅវិញទៅមកក្នុងអង្គព្រះគ្រីស្តបាន។ ការធ្វើដូច្នេះ ពួកគេនឹងបង្ហាញយ៉ាងបើកចំហនូវការគោរពប្រតិបត្តិតាមព្រះបន្ទូលព្រះជាម្ចាស់ ហើយនឹងធ្វើជាគំរូសម្រាប់គូស្វាមីភរិយាដទៃទៀតចំពោះការស្វែងរកសេរីភាពក្នុងអង្គព្រះគ្រីស្ត និងតយុទ្ធជាមួយបែបផែននៃការត្រួតត្រា និងភាពអសមធម៌ ដែលជួនកាលកើតមាននៅក្នុងក្រុមជំនុំ និងក្រុមគ្រួសារ។

*យើងជឿជាក់ថា សមធម៌តាមព្រះបន្ទូលព្រះជាម្ចាស់ ដូចដែលបានបង្ហាញនៅក្នុងឯកសារនេះ គឺជាសេចក្តីពិត ដោយយោងតាមខព្រះគម្ពីរ។*

*យើងអះអាងរួមគ្នា ដោយភាពជឿជាក់ថា ព្រះគម្ពីរ ដោយមានលក្ខណៈពេញលេញ គឺជាព្រះបន្ទូល ដែលរំដោះឲ្យមានសេរីភាព ដែលផ្តល់នូវមធ្យោបាយយ៉ាងមានប្រសិទ្ធិភាពដល់ស្ត្រី និងបុរសក្នុងការអនុវត្តនូវអំណោយទាន ដែលបានប្រទានឲ្យពីព្រះវិញ្ញាណដ៏វិសុទ្ធ ហើយដើម្បីឲ្យយើងអាចបម្រើព្រះជាម្ចាស់បាន។*

Gilbert Bilezikian

W.Ward Gasque

Stanley N.Gundry

Gretchen Gaebelein Hull

Catherine Clark Kroeger

Jo Anne Lyon

Roger Nicole

១៩៨៩, គ្រីស្ទបរិស័ទ ដើម្បីភាពសមធម៌។ ការអនុញ្ញាតឲ្យប្រើប្រាស់ឯកសារទាំងស្រុងនេះបាន
អាចទទួលយកបានពីការិយាល័យជាតិនៃអង្គការ CBE.

**គ្រីស្ទបរិស័ទ ដើម្បីភាពសមធម៌តាមព្រះបន្ទូលព្រះជាម្ចាស់**

អាស័យដ្ឋានៈ 122 ផ្លូវ West Franklin, បន្ទប់ 218, Mpls, MN 55404-2451

ទូរស័ព្ទៈ (612) 872-6898

អ៊ីមែលៈ cbe@cbeinternational.org

www.cbeinternational.org